# រឿងប្រៀបប្រដូចអំពីដើមអូលីវ ៖ យ៉ាកុប ៥

## ការបែកខ្ញែកនៃសាសន៍អ៊ីស្រាអែល

ពីមុនជំនាន់ព្រះគ្រីស្ទ ( ខទី ៣–១៤ )

ដើមអូលីវស្រុក ( សាសន៍អ៊ីស្រាអែល ) កំពុងងាប់ ( ខទី ៣–៤ ) ។

ម្ចាស់ចម្ការបានកាត់លួសវា ហើយដាក់ជី ហើយមានពីរបីមែកបានលូតលាស់ឡើង តែផ្នែកខាងចុងនៅតែងាប់ ( ខទី ៤–៦ ) ។

មែកធំៗត្រូវបានកាប់ចេញ រីឯមែកព្រៃត្រូវបានបំបៅ មែកទន់ខ្ចីត្រូវបានលាក់ ( ខទី ៧–១៤ ) ។

មែកក្រៀមស្វិតត្រូវបានដុតចោល ( ខទី ៧, ៩ ) ។

ដើមអូលីវព្រៃ ( ពួកសាសន៍ដទៃ ខទី ៧, ៩ )

មែកធម្មជាតិត្រូវបានលាក់ទុកនៅទីទំនាបបំផុតនៅក្នុងចម្ការ ។

ព្រះទតឃើញការក្បត់សាសនារបស់ពួកអ៊ីស្រាអែលបុរាណ ។ ទ្រង់បានបញ្ជូនពួកព្យាការីឲ្យប្រកាសអំពីការប្រែចិត្ត ប៉ុន្តែមានមនុស្សតែពីរបីនាក់ប៉ុណ្ណោះដែលបានស្ដាប់ ។ ទ្រង់បានបណ្ដោយឲ្យពួកទុច្ចរិតត្រូវបានបំផ្លាញបង់ ហើយនាំពួកសាសន៍ដទៃមក ។ មែកជាងនៃវង្សអ៊ីស្រាអែលសុចរិតមួយចំនួនបានខ្ចាត់ខ្ចាយពាសពេញផែនដី ។

## ពេលវេលារបស់ព្រះគ្រីស្ទ

( ខទី ១៥–២៨ )

ផ្លែល្អ ( ខទី ១៥–១៨ )

ដីអន់ ផ្លែល្អ ( ខទី ២០–២២ )

ដីកាន់តែអន់ ផ្លែល្អ ( ខទី ២៣ )

ផ្លែ ( មែកនេះមិនត្រូវបាននិយាយម្ដងទៀតទេ ខទី ២៤ )

ដីល្អ ផ្លែល្អ ផ្លែព្រៃ ( ខទី ២៥ )

ព្រះបានទតឃើញថា រាស្ត្រអ៊ីស្រាអែល ( ដើមមានឫសចាស់ ) ត្រូវបានថែ ហើយបានបញ្ចេញផ្លែល្អ ។ មែកជាងនៃវង្សអ៊ីស្រាអែលដែលបានខ្ចាត់ខ្ចាយក៏បានបញ្ចេញផ្លែល្អដែរ លើកលែងតែ សាសន៍នីហ្វៃ និង សាសន៍លេមិន ដែលខ្លះជាផ្លែល្អ និង ខ្លះជាផ្លែព្រៃ ។

## ការក្បត់សាសនាដ៏ធំ

( ខទី ២៩–៤៩ )

ផ្លែអាក្រក់ ( ខទី ២៩–៣៧ )

ផ្លែអាក្រក់ ( ខទី ៣៩, ៤៦ )

ផ្លែអាក្រក់ ( ខទី ៣៩, ៤៦ )

មានតែផ្លែអាក្រក់ ( ខទី ៣៩, ៤៦ )

ព្រះបានទតឃើញថា គ្រិស្តសាសនា ( ដើមដែលមានឫសចាស់ដុះចេញពីសាសន៍អ៊ីស្រាអែល និង សាសន៍ដទៃ ) បានពុកផុយ ប៉ុន្តែឫសនៅល្អដដែល ។ មែកធម្មជាតិដែលបានខ្ចាត់ខ្ចាយទៅនោះក៏ពុកផុយដែរ ។

## ការប្រមូលរាស្ត្រអ៊ីស្រាអែល

ដំណឹងល្អបានផ្សាយដល់ទូទាំងពិភពលោក ( ខទី ៥០–៧៦ )

មែកនៃដើមដែលបានខ្ចាត់ខ្ចាយ ត្រូវបានបំបៅជាប់នឹងដើមធម្មជាតិ ( ខទី ៥២–៥៣ ) ។

មែកនៃដើមធម្មជាតិ ត្រូវបានបំបៅជាប់នឹងដើមដែលបានខ្ចាត់ខ្ចាយ ( ខទី ៥៤–៥៦ ) ។

នៅពេលមែកធម្មជាតិលូតលាស់ឡើង មែកព្រៃត្រូវបានដុតចោល ( ខទី ៥៧–៥៨, ៦៥–៧៣ ) ។

សហស្សវត្សរ៍ ( ខទី ៧៦–៧៧ )

ដើមទាំងអស់បានក្លាយជាដើមតែមួយ ហើយបញ្ចេញផ្លែធម្មជាតិ ( ខទី ៧៤–៧៦ ) ។

នៅពេលផ្លែអាក្រក់ចូលមកក្នុងចម្ការម្ដងទៀត ផ្លែល្អនឹងត្រូវបានប្រមូលទុក ហើយចម្ការនឹងត្រូវបានដុត ( ខទី ៧៧ ) ។

ព្រះ និង អ្នកបម្រើទាំងឡាយរបស់ទ្រង់ ស្ដារភាពបរិសុទ្ធនៃដំណឹងល្អឡើងវិញ ។ ទ្រង់ និង ពួកលោកចាប់ផ្ដើមប្រមូលរាស្ត្រអ៊ីស្រាអែលដែលបានខ្ចាត់ខ្ចាយ ហើយនាំដំណឹងល្អទៅកាន់ពិភពលោកទាំងមូល ។ នៅពេលមនុស្សសុចរិតកើនឡើង នោះពួកទុច្ចរិតនឹងត្រូវបានបំផ្លាញបង់រហូតដល់គ្មានពួកទុច្ចរិតទៀតឡើយ ( ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ) ។ ពួកសុចរិតមានជ័យជម្នះរយៈពេលយូរ ( សហស្សវត្សរ៍ ) ។ នៅពេលសេចក្ដីអាក្រក់ចូលមកក្នុងពិភពលោកនេះម្ដងទៀត ព្រះនឹងបែងចែកមនុស្សសុចរិតចេញពីមនុស្សទុច្ចរិត ហើយបោសសម្អាតផែនដីដោយភ្លើង ។